# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

*រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ តុលា ឆ្នាំ ២០០៩*

## កំណត់ហេតុ សិក្ខាសាលាស្តីពីការរៀបចំ ផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឆ្នាំពីរពាន់ប្រាំបួន ខែកញ្ញា ថ្ងៃទីបួន និងប្រាំ វេលាម៉ោងប្រាំបីព្រឹក នៅសាលប្រជុំសណ្ឋាគារឆ្នេរសមុទ្រ មានរៀបចំសិក្ខាសាលាបន្តក្រោមអធិបតីភាពរបស់ឯកឧត្តម **សួង លាងហៃ** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីពិភាក្សាលើការធ្វើផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាន នៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ។

ជាកិច្ចចាប់ផ្តើមកម្មវិធី ឯកឧត្តម **សួង លាងហៃ** បានសម្តែងនូវសេចក្តីសោមនស្សរីករាយ និងថ្លែងអំណរគុណចំពោះកម្មវិធី CCJAP III តាមរយៈលោក **ម៉េន ស៊ូរុល** ដែលបានជួយឧបត្ថម្ភឱ្យអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានមកបន្តកិច្ចពិភាក្សាប្តូរយោបល់គ្នានៅខេត្តព្រះសីហនុ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួនក្នុងការបំពេញមុខងារកំណែទម្រង់ឱ្យរឹតតែប្រសើរជាងមុន។

ជាបន្ទាប់ឯកឧត្តមប្រធានបានប្រគល់តួនាទីជូនទៅលោក **ម៉េន ស៊ូរុល** ខាង CCJAPIII ដើម្បីធ្វើការបង្ហាញជូនជាបន្តរបៀបរៀបចំធ្វើផែនការសកម្មភាព។

លោក **ម៉េន ស៊ូរុល** បានមានប្រសាសន៍ជម្រាបអង្គប្រជុំថា ការជួបជុំគ្នាថ្ងៃនេះ គឺទាក់ទងនឹងការកំណត់សូចនាករ ហើយសូចនាករនេះត្រូវពិនិត្យទៅលើការងារដែលបានអនុវត្ត៤ឆ្នាំកន្លងមក និងដែលអាចវាស់វែងបាន។

១-យើងអាចវាស់បានតាមរយៈបរិមាណ (Quantity) ឧទាហរណ៍ថា តើការងារនោះមានប៉ុន្មានភាគរយជាដើម

២-យើងក៏អាចវាស់តាមរយៈគុណភាពការងារ (Quality) ដែរ។

សូចនាករត្រូវមានលក្ខណៈងាយស្រួល និងអាចវាស់វែងបាន ។

ជាបន្ទាប់ លោក **ម៉េន សុវណ្ណ** បានស្នើសុំឱ្យក្រុមដែលធ្វើការតាមទិសដៅនីមួយៗ ធ្វើការកំណត់សូចនាកររបស់ទិសដៅរៀងៗខ្លួន។

**ទិសដៅទី១៖ ផែនការកម្មវិធី និងសំណើត្រូវបានរៀបចំបានល្អប្រសើរ ជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌** (Plans and proposals are well prepared for CLJR)

**គោលបំណងទី១.១៖ រៀបចំផែនការឱ្យមានប្រសិទ្ធភាព និងប្រកបដោយគំនិតច្នៃប្រឌិត**

**យុទ្ធសាស្ត្រ៖**

១.១.១.ធានាឱ្យមន្ត្រីធ្វើផែនការមានសមត្ថភាពគ្រប់គ្រាន់

១.១.២.ធានាឱ្យមានការរៀបចំផែនការមានលក្ខណៈឯកភាព និងមានការចូលរួមទូលំទូលាយពីអ្នកពាក់ព័ន្ធផ្សេងៗ

១.១.៣.ធានាប្រសិទ្ធភាពនៃការអនុវត្តន៍ផែនការ។

**គោលបំណងទី១.២៖ ធ្វើបច្ចុប្បន្នភាពផែនការ**

**យុទ្ធសាស្ត្រ ៖**

១.២.១ ធានាឱ្យមានការត្រួតពិនិត្យផែនការឡើងវិញជាប្រចាំ

១.២.២ បង្កើតយន្តការផ្តល់ទិន្នន័យមួយដែលមានប្រសិទ្ធភាព។

**គោលបំណងទី១.៣៖ រៀបចំបញ្ចូលផែនការទៅក្នុងផែនការជាតនានា**

**យុទ្ធសាស្ត្រ៖**

១.៣.១ ធានាឱ្យមានការយល់ដឹងច្បាស់លាស់ពីផែនការ និងគោលនយោបាយជាតិនានា

១.៣.២ ធានាការចូលរួមទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធក្នុងការធ្វើសមាហរណកម្ម។

**គោលបំណងទី១.៤៖ តម្រឹមផែនការ**

**យុទ្ធសាស្ត្រ៖**

១.៤.១ ធានាឱ្យមានការយល់ដឹងច្បាស់លាស់ពីចក្ខុវិស័យ យុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់និងតុលាការ

១.៤.២ ធានាឱ្យមានភាពស៊ីចង្វាក់គ្នាក្នុងការធ្វើផែនការសម្រាប់វិស័យទាំងមូល។

***សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី១***

១. ផែនការផ្សាភ្ជាប់ទៅនឹងគោលនយោបាយ និងមានលក្ខណៈសមស្រប ងាយយល់អាចទទួលយកបាន

២. ផែនការត្រូវបានធ្វើបច្ចុប្បន្នកម្មតាមពេលវេលាកំណត់

៣. កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មាននៅក្នុងផែនការជាតិ និងផែនការពាក់ព័ន្ធ

៤. ផែនការ របស់ក្រសួងស្ថាប័នពាក់ព័ន្ធ ស្របជាមួយកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

**ទិសដៅទី២៖ ផែនការ កម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ត្រូវបានជំរុញ តាមដាន និងអនុវត្តប្រកបដោយប្រសិទ្ធភាព** (L&JR programs are effectively promoted, monitored and implemented)

**គោលបំណងទី២.១៖ ជំរុញការអនុវត្តកម្មវិធីសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និង តុលាការ**

**យុទ្ធសាស្ត្រ ៖**

២.១.១. ធ្វើការសិក្សាវិភាគ ពីសេចក្តីត្រូវការរបស់ស្ថាប័នអនុវត្ត

២.១.២. រៀបចំអង្គប្រជុំ ឬសិក្ខាសាលាដើម្បីផ្សព្វផ្សាយពីកម្មវិធីសកម្មភាព

២.១.៣. បង្កើត និងបន្តពង្រឹងយន្តការទំនាក់ទំនងរបស់ស្ថាប័នអនុវត្ត

២.១.៤. បង្កើតយន្តការលើកទឹកចិត្តដល់មន្ត្រីនិងស្ថាប័នអនុវត្ត

២.១.៥. បង្កើត ពង្រឹង និងបន្តការសហការជាមួយដៃគូអភិវឌ្ឍន៍

២.១.៦ ធ្វើសមាហរណកម្មនយោបាយរបស់ថ្នាក់ដឹកនាំ។

**គោលបំណងទី២.២៖ តាមដានការអនុវត្តកម្មវិធីសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ**

**យុទ្ធសាស្ត្រ៖**

២.២.១ បង្កើតយន្តការតាមដានសកម្មភាពកំណែទម្រង់

២.២.២ ពង្រឹងសមត្ថភាពបច្ចេកតាមដាន និង ប្រភពធនធានរបស់អគ្គលេខាធិការដ្ឋាន និង

២.២.៣ ពង្រឹងយន្តការពត៌មានឆ្លើយតបដើម្បីធានាថាពត៌មានត្រូវយកមកធ្វើជាមូលដ្ឋានសម្រាប់ ការធ្វើផែនការ

**គោលបំណងទី២.៣៖ អនុវត្តកម្មវិធី ឬគម្រោងដែលចាំបាច់ពាក់ព័ន្ធនឹងកម្មវិធីសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ**

**យុទ្ធសាស្ត្រ៖**

២.៣.១ កំណត់គម្រោង ឬសកម្មភាពដែលត្រូវអនុវត្តដោយអគ្គលេខាធិការដ្ឋាន

២.៣.២ រៀបចំផែនការសម្រាប់អនុវត្ត និង រកប្រភពធនធានសម្រាប់អនុវត្ត

២.៣.៣ ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពគ្រប់គ្រងគម្រោងរបស់អគ្គលេខាធិការដ្ឋាន និងស្ថាប័នអនុវត្ត។

**គោលបំណងទី២.៤៖ ពង្រឹងការអនុវត្តន៍កម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ**

**យុទ្ធសាស្ត្រ៖**

២.៤.១ លើកសំណើគម្រោង និងជួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំសំណើគម្រោង

២.៤.២ ស្វែងរកការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកម្ពុជា

២.៤.៣ ធានាតួនាទីដឹកនាំ/ណែនាំក្នុងការអនុវត្តន៍គម្រោង។

***<u>សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី២</u>***

**១. ចំនួនភាគរយនៃការអនុវត្តកម្មវិធីសកម្មភាពរយៈពេល ខ្លី មធ្យម វែង**

**២. ប្រព័ន្ធសូចនាករ និងការតាមដាន អនុវត្តទូលំទូលាយដោយស្ថាប័នអនុវត្ត**

**៣. គម្រោងរៀបចំដោយអគ្គលេខាធិការដ្ឋានត្រូវបានអនុវត្ត។**

**ទិសដៅទី៣៖ ស្ថាប័នអនុវត្ត និងដៃគូអភិវឌ្ឍន៍មានការសម្របសម្រួលប្រកបដោយ ប្រសិទ្ធភាព**

(Implementing institutions and development partners are effectively coordinated)

**គោលបំណងទី៣.១៖ ជំរុញកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធ**

**យុទ្ធសាស្ត្រ៖**

៣.១.១ រៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់ជាមួយអ្នកពាក់ព័ន្ធ

៣.១.២ ពង្រឹងយន្តការសម្របសម្រួលដែលមានស្រាប់ (Sub-Group, TWG)

៣.១.៣ រៀបចំឱ្យមានយន្តការមន្ត្រីបង្គោលតាមស្ថាប័នពាក់ព័ន្ធ។

**គោលបំណងទី៣.២៖ ជំរុញឱ្យមានការផ្លាស់ប្តូរព័ត៌មានប្រកបដោយប្រសិទ្ធភាព**

**យុទ្ធសាស្ត្រ៖**

៣.២.១ បង្កើតយន្តការតាមដាន

៣.២.២ បង្កើតយន្តការផ្លាស់ប្តូរព័ត៌មានជាមួយភ្នាក់ងារកំណែទម្រង់ផ្សេងៗ និងជាមួយអ្នកពាក់ព័ន្ធ

៣.២.៣ ផ្តល់លទ្ធភាពទទួល និងចែកចាយព័ត៌មាន។

**គោលបំណងទី៣.៣៖ ពង្រឹងការផ្សព្វផ្សាយព័ត៌មានកំណែទម្រង់ច្បាប់ និងតុលាការ**

**យុទ្ធសាស្ត្រ៖**

៣.៣.១ ធានាបាននូវការទទួលព័ត៌មានអេឡិចត្រូនិចប្រកបដោយភាពជឿទុកចិត្ត

៣.៣.២ ធ្វើឱ្យប្រសើរឡើងនូវការផ្សព្វផ្សាយព័ត៌មានច្បាប់ និងតុលាការ

៣.៣.៣ ពង្រឹងយុទ្ធសាស្ត្រទំនាក់ទំនង *(ពង្រឹងការចែករំលែកព័ត៌មានផ្ទៃក្នុង )"មន្ត្រីទំនាក់ទំនង"*

**គោលបំណងទី៣.៤៖ សម្របសម្រួលស្ថាប័នពាក់ព័ន្ធអនុវត្តតាមគោលការណ៍ «ប្រសិទ្ធភាពនៃជំនួយ »**

**យុទ្ធសាស្ត្រ ៖**

៣.៤.១ ធានាថាមានតំណាងរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅក្នុងគណៈកម្មាធិការគម្រោងនានា ដែលពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៣.៤.២ ធានាឱ្យមានតំណាងរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅក្នុងស្ថាប័នជាតិ និងតំបន់ក្នុងវិស័យកំណែទម្រង់នានា

៣.៤.៣ ពិនិត្យគម្រោងដែលកំពុងមាន និងគម្រោងដែលកំពុងស្នើសុំ ដើម្បីធានាឱ្យបានគម្រោងទាំងនោះ តម្រឹមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

***<u>សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី៣</u>***

1. **ចំនួនកើនឡើង នៃយន្តការសម្របសម្រួល និងកិច្ចប្រជុំទៀងទាត់ជាមួយស្ថាប័នពាក់ព័ន្ធ**
2. **ចំនួនកើនឡើង នៃកម្មវិធីសហប្រតិបត្តិការ ជាមួយអ្នកពាក់ព័ន្ធ**
3. **ភាគរយ នៃការយល់ដឹង របស់ប្រជាពលរដ្ឋ អំពីកំណែទម្រង់ច្បាប់ និងតុលាការកើនឡើង**
4. **ឯកសារយុទ្ធសាស្ត្រទំនាក់ទំនងត្រូវបានអនុម័ត និងអនុវត្ត**
5. **ចំនួនគម្រោងកម្មវិធី តម្រឹមតាមកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការកើនឡើង**

**ទិសដៅទី៤៖ ក្រសួងស្ថាប័នពាក់ព័ន្ធទទួលបានជំនួយបច្ចេកទេសតាមការចាំបាច់** (Relevant institutions have access to technical assistance as required)

**គោលបំណងទី៤.១៖ កំណត់ពីតម្រូវការជំនួយបច្ចេកទេស**

**យុទ្ធសាស្ត្រ**

៤.១.១ សិក្សាស្រាវជ្រាវពីតម្រូវការជំនួយបច្ចេកទេសរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ

៤.១.១.១ ប្រមូល និងចងក្រងទិន្នន័យ(សកម្មភាព)

៤.១.១.២ វិភាគ និងលើកអនុសាសន៍(សកម្មភាព)។

**គោលបំណងទី៤.២៖ ពង្រឹងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធឱ្យបានប្រសើរឡើង យុទ្ធសាស្ត្រ៖**

៤.២.១ បង្កើតកម្មវិធីបណ្តុះបណ្តាលស្របតាមតម្រូវការ

៤.២.២ បង្កើតមជ្ឈមណ្ឌលឯកសារតាមស្ថាប័ន

៤.២.៣ ពង្រឹងការគ្រប់គ្រងធនធានមនុស្ស

៤.២.៤ ពង្រឹងយន្តការទំនាក់ទំនងឱ្យមានប្រសិទ្ធភាព

៤.២.៥ ធានាការប្រឹក្សាយោបល់ផ្នែកជំនួយបច្ចេកទេស និងការផ្តល់ព័ត៌មាន។

***<u>សូចនាករតាមដានការអនុវត្តន៍សម្រាប់ទិសដៅទី៤</u>***

**១. ក្រសួងស្ថាប័នពាក់ព័ន្ធទទួលជំនួយបច្ចេកទេសពីអគ្គលេខាធិការដ្ឋានកើនឡើង**

**២. ការបណ្តុះបណ្តាលសមត្ថភាពសម្រាប់អគ្គលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ កើនឡើង**

កិច្ចប្រជុំរៀបចំធ្វើផែនការយុទ្ធសាស្ត្រសម្រាប់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានចប់សព្វគ្រប់ប្រកបដោយបរិយាកាសរីករាយក្រៃលែង ឯកឧត្តមប្រធានបានថ្លែងអំណរគុណដល់ តំណាង CCJAP&DANIDA ដែលខំចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងចំណាយនូវថវិកាមួយចំនួនសម្រាប់គាំទ្រ នូវការរៀបចំធ្វើសិក្ខាសាលាចំនួនពីរលើកមកនេះ គឺទី១-សិក្ខាសាលានៅខេត្តកោះកុង និងទី២-សិក្ខាសាលានៅខេត្តព្រះសីហនុ។ ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមប្រធានបានថ្លែងអំណរគុណផងដែរ ចំពោះសមាជិករបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានខិតខំយកចិត្តទុកដាក់ និងសហការក្នុងការរួមមតិយោបល់រួមគ្នាមកចងក្រងធ្វើជាផែនការយុទ្ធសាស្ត្រមួយ ដ៏ពេញលេញសម្រាប់អនុវត្តការងារផ្ទាល់របស់ខ្លួន។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់ នាថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៩។

**បានឃើញ និងឯកភាព**

អគ្គលេខាធិការរង | អ្នកធ្វើរបាយការណ៍

សួង លាងហៃ | សេង វ៉ាន់ដា

## បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
## នាថ្ងៃទី០៤-០៥ ខែកញ្ញា ឆ្នាំ២០០៩

០១- ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរង ( កកចយ )

០២- ឯកឧត្តម ប៉ែន ប៊ុនឈា អគ្គលេខាធិការរង ( កកចយ )

០៣- ឯកឧត្តម ប្ញូន សុមុនី អគ្គលេខាធិការរង ( កកចយ )

០៤- ឯកឧត្តម ផៃ សុខខេង ប្រធានផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ( កកចយ )

០៥- ឯកឧត្តម ផែ លី អនុប្រធានផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ( កកចយ )

០៦- លោក ជឹង ផេងស្រួយ ប្រធានផ្នែកបណ្ណ័សារ និងព័ត៌មានវិទ្យា ( កកចយ )

០៧- លោកស្រី ស្រី ប៊ុណ្ណារ័ត្ន អនុប្រធានផ្នែកបណ្ណ័សារ និងព័ត៌មានវិទ្យា ( កកចយ )

០៨- លោក គង់ ផល្លះ អនុប្រធានផ្នែកកំណែទម្រង់ច្បាប់ ( កកចយ )

០៩- លោក ឃ្លោក ដារ៉ា ប្រធានផ្នែកលើកកំពស់សិទ្ធិមនុស្ស និងមជ្ឈត្តកម្ម ( កកចយ )

១០- លោកស្រី ឈ្យូក សារ៉ុម ប្រធានការិយាល័យ ( កកចយ )

១១- លោកស្រី យិន កក្កដា ប្រធានការិយាល័យ ( កកចយ )

១២- លោកស្រី សេង វ៉ាន់ដា ប្រធានការិយាល័យ ( កកចយ )

១៣- លោក ស៊ុន សិរីវុធ មន្ត្រី ( កកចយ )

១៤- លោក ហ៊ូវ ភត្រា មន្ត្រី ( កកចយ )

១៥- លោក សួន វិរៈ មន្ត្រី ( កកចយ )

១៦- កញ្ញា ជា សុភី មន្ត្រី ( កកចយ )

១៩- លោក ជ សៀកវែង (CCJAP III)

២០-កញ្ញា ចំរើន សាវត្ថី មន្ត្រី ( កកចយ )

១៧- Ben Schultz(CCJAP III)

១៨- Mr. Michael Engquist (NANIDA)